ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
## ស្តីពី
## លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែកញ្ញា ឆ្នាំ២០២៣

នៅក្នុងខែកញ្ញា ឆ្នាំ២០២៣នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

១.១-សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

១.១.១-បដិសណ្ឋារកិច្ចឡើងជាតិ-អន្តរជាតិ

-បានអនុញ្ញាតឱ្យ ឯកឧត្តម **សេដ្ឋា ថាវីស៊ីន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ និងគណៈប្រតិភូ ចូលជួបសវនាការ និងសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា

-បានអនុញ្ញាតឱ្យ ឯកឧត្តម Kim Jin Pyo ប្រធានរដ្ឋសភានៃសាធារណរដ្ឋកូរ៉េចូលជួបសម្តែងការគួរសម និងសវនាការ នៅវិមានព្រឹទ្ធសភា

-បានអនុញ្ញាតឱ្យ ឯកឧត្តម Gaman Oleksandr ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋអ៊ុយក្រែន ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជូនសារតាំង នៅវិមានព្រឹទ្ធសភា

-បានអនុញ្ញាតឱ្យ ឯកឧត្តម Shovgi Kamal Oglu Mehdizada ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋអាស៊ែបៃហ្សង់ ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជូនសារតាំង នៅវិមានព្រឹទ្ធសភា។

១.១.២-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានចុះហត្ថលេខាលើព្រះរាជក្រឹត្យ ចំនួន១១៨ច្បាប់

-បានចុះហត្ថលេខាលើសំណើសុំព្រះរាជទានសិទ្ធិ ចំនួន១០២ច្បាប់

-បានទទួលព្រះរាជសារព្រះរាជទានសិទ្ធិ ចំនួន១០២ច្បាប់

-បានទទួលសំណើពីរាជរដ្ឋាភិបាល ចំនួន៨៩ច្បាប់

-បានទទួលសំណើពីក្រសួងព្រះបរមរាជវាំង ចំនួន០១ច្បាប់

-បានទទួលសំណើពីរដ្ឋសភា ចំនួន១០ច្បាប់

-បានទទួលសំណើពីក្រុមប្រឹក្សាធម្មនុញ្ញ ចំនួន០២ច្បាប់

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន០២ច្បាប់ និងជ្រាបជា



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

ព័ត៌មាន ចំនួន៦៨ច្បាប់។

**១.២-ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុម កា អនុប្រធានទី១ព្រឹទ្ធសភា**

១.២.១-សកម្មភាពចូលរួមកិច្ចប្រជុំ

-បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន០២លើក និងដឹកនាំកិច្ចប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ចំនួន០១លើក

១.២.២-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន២៥ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន៥៤ច្បាប់។

**១.៣-ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ព្រឹទ្ធសភា**

១.៣.១-សកម្មភាពចូលរួមកិច្ចប្រជុំ

-បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន០២លើក និងចូលរួមកិច្ចប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ចំនួន០១លើក

១.៣.២-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញចូលរួមជាគណៈអធិបតីក្នុងពិធីអបអរសាទរការចុះបញ្ជីរមណីយដ្ឋានប្រាសាទកោះកេរ ចូលជាសម្បត្តិបេតិកភណ្ឌវប្បធម៌ពិភពលោក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅពហុកីឡដ្ឋានជាតិអូឡាំពិក។

-បានអញ្ជើញចូលរួមជាគណៈអធិបតីក្នុងពិធីអបអរសាទរក្នុងឱកាសខួបលើកទី៦៥ នៃការបង្កើតទំនាក់ទំនងការទូតរវាងសាធារណរដ្ឋប្រជាមានិតចិន និងព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពឯកឧត្តម Wang Wentian ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំនៅកម្ពុជា និងលោកជំទាវ GU Xiaojun។

១.៣.៣-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន១៦ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន២៣ច្បាប់។

## ២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

ព្រឹទ្ធសភាបានបើកកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចំនួន០២លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុម កា** ប្រធានស្តីទីព្រឹទ្ធសភា ដើម្បីពិនិត្យសំណើរបស់រដ្ឋសភា និងគណៈកម្មការជំនាញ លើសេចក្តីព្រាងច្បាប់ ចំនួន០២ច្បាប់ និងពិនិត្យ សម្រេចលើរបាយការណ៍ ស្តីពីលទ្ធផល និងសកម្មភាពការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី១០ និងលើកទី១១ នីតិកាលទី៤។

## ៣.សម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ

ព្រឹទ្ធសភាបានបើកកិច្ចប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ចំនួន០១លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា** ប្រធានស្តីទីព្រឹទ្ធសភា ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ចំនួន០២ច្បាប់ ដូចខាងក្រោម៖

១-សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតក្រសួងអធិការកិច្ច

២-សេចក្តីព្រាងច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។

## ៤-គណៈកម្មការនានារបស់ព្រឹទ្ធសភា

សមាជិក សមាជិកាព្រឹទ្ធសភាបានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ៤.១ មុខងារនីតិកម្ម

-បានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការជាមួយតំណាងរាជរដ្ឋាភិបាលដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ចំនួន០២ច្បាប់។

### ៤.២-មុខងារតាមដានការអនុវត្តច្បាប់

-បានអញ្ជើញចុះបេសកកម្មសិក្សាឈ្វេងយល់ស្តីពី ការអភិវឌ្ឍមូលដ្ឋាន និងបម្រើសេវាជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព ធានាបានសុខសន្តិភាព នៅខេត្តព្រៃវែង

-បានអញ្ជើញចុះបេសកកម្មសិក្សាឈ្វេងយល់ និងជួបពិភាក្សាការងារជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ច ប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងក្រៀល ខេត្តស្ទឹងត្រែង ដើម្បីប្រមូលព័ត៌មានឱ្យកាន់តែស៊ីជម្រៅអំពីវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ដូចជា៖ ការអនុវត្តច្បាប់អន្តោប្រវេសន៍ អន្តោប្រវេសន្ត ការគ្រប់គ្រងជនបរទេសឆ្លងដែន សកម្មភាពចេញ-ចូលរបស់ភ្ញៀវជាតិ-អន្តរជាតិ និងសកម្មភាពផ្ទេរទំនិញ ព្រមទាំងបង្កើនទំនាក់ទំនងជិតស្និទ្ធរវាងគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាននៃព្រឹទ្ធសភា ជាមួយប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិ

-បានអញ្ជើញទស្សនកិច្ចប្រាសាទនានានៅក្នុងតំបន់ប្រាសាទបាកាន ស្ថិតនៅក្នុងភូមិបាកាន ឃុំរណសិរ្ស ស្រុកសង្គមថ្មី ខេត្តព្រះវិហារ ដើម្បីឈ្វេងយល់អំពីការគ្រប់គ្រង កិច្ចអភិរក្ស និងការអភិវឌ្ឍវិស័យទេសចរណ៍នៅក្នុងតំបន់ប្រាសាទបាកាន

-បានអញ្ជើញចុះសិក្សាឈ្វេងយល់ និងប្រមូលព័ត៌មានអំពីការផ្សព្វផ្សាយច្បាប់ និងការអនុវត្ត

ច្បាប់ពាក់ព័ន្ធនឹងវិស័យជំនាញជាសមត្ថកិច្ចរបស់គណៈកម្មការ ផ្តោតលើការផ្តល់សេវាបណ្តុះបណ្តាលវិជ្ជាជីវៈ និងការគ្រប់គ្រងថែទាំកុមារ នៅខេត្តកំពត និងខេត្តកែប ដោយជួបជាមួយអាជ្ញាធរខេត្តកំពត ចុះទស្សនកិច្ច និងជួបសំណេះសំណាលជាមួយមន្ត្រី គ្រូបច្ចេកទេស និងបុគ្គលិកនៅវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនកំពត និងកុមារកំព្រានៅមជ្ឈមណ្ឌលបុរីកុមារខេត្តកែប

-បានអញ្ជើញចុះសិក្សាឈ្វេងយល់អំពីដំណើរការនៃការកសាងអាកាសយានដ្ឋានអន្តរជាតិសៀមរាប, ការធ្វើទំនើបកម្មនៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធជាតិត្រួតពិនិត្យសុវត្ថិភាពអាកាសចរស៊ីវិល នៅខេត្តសៀមរាប

-បានអញ្ជើញចុះទស្សនកិច្ចការងារ និងសិក្សាឈ្វេងយល់អំពីការអនុវត្តច្បាប់ ស្តីពីការប្រឆាំងអំពើពុករលួយ និងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ នៅខេត្តសៀមរាប

-បានអញ្ជើញចុះបេសកកម្មសិក្សាឈ្វេងយល់ និងជួបពិភាក្សាការងារជាមួយអាជ្ញាធរខេត្ត, ប្រធានមន្ទីរអប់រំ យុវជន និងកីឡា, ប្រធានមន្ទីរធម្មការ និងសាសនា, ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ និងប្រធានមន្ទីរទេសចរណ៍ ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ។

### ៤.៣-មុខងារតំណាង

-បានធ្វើកំណត់បង្ហាញពាក្យបណ្តឹង ចំនួន០២ករណី បញ្ជូនពាក្យបណ្តឹងទៅក្រសួង-ខេត្ត និងស្ថាប័នពាក់ព័ន្ធ ចំនួន០២ករណី កំពុងពិនិត្យសិក្សា ចំនួន០២ករណី ឆ្លើយតបទៅម្ចាស់បណ្តឹង ចំនួន០២ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងពីស្ថាប័នពាក់ព័ន្ធ ចំនួន០២ករណី ព្រមទាំងបានទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ចំនួន០៤ករណី

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីខួបអនុស្សាវរីយ៍លើកទី៣៣ ថ្ងៃប្រកាសបង្កើតកងវរសេនាតូចលេខ២៤៦ និងខួបអនុស្សាវរីយលើកទី១៤ ថ្ងៃប្រកាសបង្កើតបញ្ជាការដ្ឋានអង្គរក្សនៅខេត្តកណ្តាល

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ ចំនួន០៣លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា រួមមាន៖ ពិធីសំណេះសំណាលជាមួយកម្មករ និយោជិត, ពិធីអបអរសាទរការចុះបញ្ជីរមណីយដ្ឋានប្រាសាទកោះកេរ ចូលជាសម្បត្តិបេតិកភណ្ឌវប្បធម៌ពិភពលោក, ចូលរួមប្រជុំសភាពាណិជ្ជកម្ម ក្នុងនាម

ជាសហប្រធានក្រុមការងារ ក/ទី១ ផ្នែកកសិកម្ម កសិឧស្សាហកម្ម នៃវេទិការាជរដ្ឋាភិបាល និងផ្នែកឯកជន ដើម្បីត្រៀមចូលរួមវេទិការាជរដ្ឋាភិបាល និងផ្នែកឯកជនលើកទី១៩ នៅរាជធានីភ្នំពេញ ខេត្តកណ្ដាល និងខេត្តកំពង់ស្ពឺ

-ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន យុវជន-យុវនារី ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខសណ្ដាប់ធ្នាប់ ការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ ជួយប្រជាពលរដ្ឋជួបគ្រោះធម្មជាតិ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានី និងតាមបណ្ដាខេត្ត ក្រុងនានា ចំនួន៧៥លើក ព្រមទាំងបានអញ្ជើញជាគណៈអធិបតីក្នុងពិធីសម្ពោធសមិទ្ធផលនានា និងចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗ ចំនួន៤៧លើក។

### ៤.៤-កិច្ចសហប្រតិបត្តិការអន្តរជាតិ

ការងារសហប្រតិបត្តិការអន្តរជាតិរបស់ព្រឹទ្ធសភា ជាពិសេស ទំនាក់ទំនងក្នុងកម្រិតតំបន់ និងអន្តរជាតិ សមាជិក សមាជិកាព្រឹទ្ធសភា បានចូលរួមយ៉ាងសកម្ម និងទទួលបានលទ្ធផលជាវិជ្ជមានដូចខាងក្រោម៖

-បានអញ្ជើញចូលរួមក្នុងជំនួបសម្ដែងការគួរសមរវាង សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ជាមួយឯកឧត្តម Kim Jin Pyo ប្រធានរដ្ឋសភានៃសាធារណរដ្ឋកូរ៉េ នៅវិមានព្រឹទ្ធសភា

-បានអញ្ជើញជាអធិបតីក្នុងពិធីបើកកិច្ចសន្ទនាកម្រិតថ្នាក់ជាតិ ស្ដីពីកិច្ចប្រជុំកម្រិតខ្ពស់របស់អង្គការសហប្រជាជាតិស្ដីពីជំងឺរបេងឆ្នាំ២០២៣ នៅរាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរខួបលើកទី៧៨ នៃទិវាបុណ្យឯករាជ្យជាតិនៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅរាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរខួបលើកទី៧០ នៃទំនាក់ទំនងមិត្តភាពជប៉ុន-កម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម UENO Atsushi ឯកអគ្គរាជទូតវិសាមញ្ញ និង

ពេញសមត្ថភាព នៃព្រះរាជាណាចក្រជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា នៅអគារ CJCC Angkor Kizuna Hall សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

-បានអញ្ជើញទទួលជួបក្រុមអ្នកវិនិយោគជនជាតិជប៉ុន និងចិន ដែលមានបំណងចង់បណ្តាក់ទុនវិនិយោគលើវិស័យកសិឧស្សាហកម្ម ឧស្សាហកម្មកែច្នៃ និងសិក្សាឈ្វេងយល់លើវិស័យកសិកម្ម និងកសិឧស្សាហកម្ម នៅព្រះរាជាណាចក្រកម្ពុជា។

ថ្ងៃ អង្គារ ៤ រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែតុលា ឆ្នាំ២០២៣

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**កិត្តិសង្គហបណ្ឌិត ឡេព ខន**

<u>ចម្លងជូន</u>

- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
  (ជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ